# អនុក្រឹត្យលេខ ០៣ អនក្រ.បក

## ស្តីពីការផ្ទេរឥណទានថវិកា

===

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ១៩៩៩

-បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ២០០១

-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១.-**

ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ជូនក្រសួងការពារជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោមនេះ :

| ជំពូក | ការរាយមុខ | ស្ថានភាពឥណទានដើមឆ្នាំ | ចលនាឥណទាន | | ស្ថានភាពឥណទានថ្មី |
|---|---|---|---|---|---|
| | | | កើន | ថយ | |
| | **០៦.ក្រសួងការពារជាតិ** | | | ២០.៨០០ | |
| | **ការផ្ទេរចេញ** | | | ២០.៨០០ | |
| ១០ | បៀវត្ស និងប្រាក់បំណាច់ | ២០៨.០០០ | - | ១៨.៦០០ | ១៨៩.៤០០ |
| ៣១ | អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ | ១១.៨០០ | - | ២.២០០ | ៩.៦០០ |
| | **ការផ្ទេរចូល** | | ២០.៨០០ | | |
| ១១ | ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច | ៥៧.៦៦០ | ២០.៨០០ | - | ៧៨.៤៦០ |
| | **ការផ្ទេរចេញ** | | | ៧៦.០០០ | |
| | **៩៩.ចំណាយមិនទាន់បែងចែក** | | | ៧៦.០០០ | |
| ២០ | ការប្រាក់លើការខ្ចីបុល រយៈពេលវែង មធ្យម និងខ្លី | ២៥.០០០ | - | ២៥.០០០ | - |
| ១២ | ប្រាក់ឧបត្ថម្ភ សំរាប់ដំណើរការអង្គការសាធារណៈរដ្ឋបាល | ២៦.០០០ | - | ២៦.០០០ | - |
| ៥៣ | ការទូទាត់បំណុល | ២៥.០០០ | - | ២៥.០០០ | - |
| | **ការផ្ទេរចូល** | | ៧៦.០០០ | | |
| | **១០.ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | | ៧៦.០០០ | | |
| ២០ | ការប្រាក់នៃការខ្ចី រយៈពេលវែង មធ្យម និងខ្លី | - | ២៥.០០០ | - | ២៥.០០០ |

| | | | | | |
|---|---|---|---|---|---|
| ១២ | ប្រាក់ឧបត្ថម្ភ សំរាប់ដំណើរការអង្គការសាធារណៈរដ្ឋបាល | - | ២៦.០០០ | - | ២៦.០០០ |
| ៩៣ | ការរំលស់បំណុល | - | ២៥.០០០ | - | ២៥.០០០ |

**មាត្រា ២.-**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០១ តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមករា ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

***

## អនុក្រឹត្យលេខ ០៤ អនក្រ.បក

## ស្តីពីការកាត់បន្ថយដែនសេវាកម្មឧទ្យានជាតិគីរីរម្យ ខេត្ត កំពង់ស្ពឺ ទុកសំរាប់ប្រជាពលរដ្ឋធ្វើសេវាកម្មជាលក្ខណៈគ្រួសារ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា